# បឋអប់ទី១

## ស្តីអំពី: តួនាទីវត្តអារាមនិងគណៈសង្ឃ

បុគ្គលិកលក្ខណៈ: "វត្តអារាមជាមជ្ឈមណ្ឌលផ្សព្វផ្សាយវប្បធម៌ខ្មែរ និងផ្តល់ព័ត៌មានពិតដល់ប្រជាជន"

ព្រះពុទ្ធសាសនា នៅកម្ពុជាមានរចនាសម្ព័ន្ធ គ្រប់គ្រង ដឹកនាំជាឋានានុក្រម ពីថ្នាក់កំពូលរហូតដល់ថ្នាក់មូលដ្ឋាន គឺវត្តអារាមនេះឯង ។ នៅថ្នាក់កំពូលមានសម្តេចព្រះសង្ឃរាជនិងមន្ត្រីសង្ឃថ្នាក់ជាគណៈ និងឋានានុក្រមជាបន្តបន្ទាប់ ។ នៅថ្នាក់ខេត្តមានមេគណខេត្ត នៅថ្នាក់ស្រុកមានអនុគណស្រុក នៅថ្នាក់មូលដ្ឋាន មានគ្រូចៅអធិការ និងគ្រូសូត្រស្តាំ គ្រូសូត្រឆ្វេង ហើយបច្ចុប្បន្ននេះ មានវត្តខ្លះបានបន្ថែមព្រះវិន័យធរ និងលេខាធិការសម្រាប់វត្តជាជំនួយការទៀតផង ។

មុនឆ្នាំ **១៨៥៤** ព្រះពុទ្ធសាសនានៅកម្ពុជាមានតែមួយគណៈទេគឺគណៈមហានិកាយ រីឯគណៈធម្មយុត្តិក-និកាយ មានដើមកំណើតនៅប្រទេសសៀម(ថៃ) ក្នុងឆ្នាំឆ្លូវឯកស័ក **ច.ស.១១៩១** ត្រូវនឹង **គ.ស.១៨២៩** ដោយយោងទៅលើប្រវត្តិសាស្ត្រពុទ្ធសាសនានៅកម្ពុជា នាសម័យឧដុង្គ សម្តេច**សុគន្ធាធិបតី មហាប៉ាន** បាននិមន្តទៅរៀននៅប្រទេសថៃ ហើយបាននិមន្តទៅគង់នៅវត្ត**បវរនិវាស** ដែលជាវត្តធម្មយុត្ត ដំបូងបំផុតកសាងឡើងដោយ**ព្រះចមក្លាវ** ។ ពេលដែលលោកត្រឡប់មកប្រទេសកម្ពុជាវិញ លោកក៏បានសូមព្រះរាជានុញ្ញាតបង្កើត គណៈធម្មយុត្តិកនិកាយនៅកម្ពុជា ទើបបានជាមានគណៈធម្មយុត្តតាំងពីពេលនោះមក ។

**ចំពោះសមណសក្តិ តាមបវេណីព្រះពុទ្ធសាសនាកម្ពុជាតាំងពីបុរាណរៀងមករួមមាន៖**

ក- សម្តេចសង្ឃ ខ- សង្ឃនាយក

គ- រាជាគណៈ ឃ- ឋានានុក្រម

ង- មហា ហើយចែកជាបួនថ្នាក់គឺ ឯក ទោ ត្រី ចត្វា។

សមណសក្តិរាជាគណៈមាន ៣២ រួមមាន ៖

- ថ្នាក់ឯកមាន ១១ (ផ្ចិតពណ៌ក្រហម)
- ថ្នាក់ទោមាន ៧ (ផ្ចិតពណ៌បៃតង)
- ថ្នាក់ត្រីមាន ៧ (ផ្ចិតពណ៌ស្វាយ)
- ថ្នាក់ចត្វាមាន ៧ (ផ្ចិតពណ៌ខៀវ)

តែមកដល់ គ.ស.១៩២៣ មានការកែប្រែបន្ថែមបន្ថយខ្លះ ហើយមកដល់ គ.ស.១៩២៨ បានកែប្រែម្តងទៀតដោយចែកជាពីរគណៈគឺ ៖

<u>មហានិកាយ និងធម្មយុត្តិកនិកាយ</u>

-ព្រះសង្ឃនាយកគណៈមហានិកាយ (សម្តេចសង្ឃរាជ) រាជាគណៈមាន ៣៥ គឺ ៖

ក- ថ្នាក់ឯកមាន៣ ខ- ថ្នាក់ទោមាន៦

គ- ថ្នាក់ត្រីមាន៦ ឃ- ថ្នាក់ចត្វាមាន២០

-ព្រះសង្ឃនាយកគណៈធម្មយុត្តិកនិកាយ ព្រះសុគន្ធាធិបតី (សម្តេចសង្ឃរាជ) រាជាគណៈមាន ២១ គឺ ៖

ក- ថ្នាក់ឯកមាន២ ខ- ថ្នាក់ទោមាន៣

គ- ថ្នាក់ត្រីមាន៤ ឃ- ថ្នាក់ចត្វាមាន១២

សូមបញ្ជាក់ថាព្រះសង្ឃនាយក សម្តេចទាំងពីរព្រះអង្គ មហាក្សត្រទ្រង់ប្រោសព្រះរាជទានតែងតាំងដោយព្រះរាជក្រឹត្យ ។

**សំណួរ:** តើការតែងតាំងឬក៏ផ្តល់សមណសក្តិតួនាទីទាំងអស់នេះមានប្រយោជន៍អ្វីខ្លះ សម្រាប់ព្រះពុទ្ធសាសនានៅកម្ពុជា?

**ចម្លើយ:** ទំនងមានច្រើនយ៉ាង ប៉ុន្តែខ្ញុំសូមរៀបរាប់ខ្លីៗ សម្រាប់ការយល់ដឹងទាំងអស់គ្នា



ទី១. អភិបាលកិច្ចសង្គមសង្ឃ

ទី២. ដើម្បីរៀបចំសណ្តាប់ឲ្យបានល្អក្នុងសង្គមសង្ឃ

ទី៣.ដើម្បីជាបណ្តាញផ្សព្វផ្សាយខ្លឹមសារធម៌ព្រះពុទ្ធ ដល់សង្គមជាតិនិងពិភពលោកទាំងមូល ។ ហើយព្រះសង្ឃ ដែលមានតំណែងទាំងនេះ មានឥទ្ធិពលខ្លាំងណាស់ក្នុងការ ឃោសនាផ្សព្វផ្សាយអប់រំខាងទ្រឹស្តីព្រះពុទ្ធសាសនា ក៏ដូច ជាពត៌មានពិតផ្សេងៗ ។ ដូច្នេះហើយ បានជាឯកសារច្បាប់ ទម្លាប់ ក្បួនខ្នាត រឿងរ៉ាវ និងពត៌មានផ្សេងៗបានរីកសាយ ភាយ យ៉ាងឆាប់រហ័សចូលដល់ភូមិស្រុក និងដល់ផ្ទះប្រជា ជន ។ អ្វីដែលខ្ញុំបានសរសេរខាងលើនេះ គឺជាការផ្ទេរមរតក វប្បធម៌របស់ជាតិ និងពុទ្ធសាសនាពីជំនាន់មួយឲ្យទៅជំនាន់ មួយទៀត ។ ឧទាហរណ៍: ដូចជាក្នុងសម័យបុរាណយើង មានសិលាចារឹក ២.០០០ផ្ទាំង (ជាភាសាខ្មែរ និងភាសា សំស្ក្រឹត) នៅសម័យកណ្តាលមានសាស្ត្រាស្លឹករឹតរាប់ពាន់ ច្បាប់ មានក្រាំង មានគម្ពីររាប់ពាន់ក្បាលដែលបានកំពុង នឹងផ្សព្វផ្សាយទៅតាមបណ្ណាល័យ សាលារៀន វត្តអារាម និងអន្តរបណ្តាញ(Internet) ។ រីឯព្រះសង្ឃអ្នកអាន អ្នក

ទេសនា អ្នកស្មូធ្យកាព្យ ក៏បានកើតមានយ៉ាងផុសផុលក្នុងសង្គមខ្មែរបច្ចុប្បន្ន ។

**សំណួរ:** តើបច្ចុប្បន្ន មន្ត្រីសង្ឃគ្រប់ឋានានុក្រមបានធ្វើអ្វីខ្លះ ចំពោះសង្គមពុទ្ធសាសនានៅកម្ពុជា?



**ចម្លើយ:** សម្រាប់ខ្ញុំដែលមិនមែនជាមន្ត្រីសង្ឃ គឺពិបាកនឹងឆ្លើយនូវសំណួរនេះណាស់ តែខ្ញុំសូមឆ្លើយដោយការ មើលឃើញដោយផ្ទាល់ទៅចុះ ព្រោះខ្ញុំក៏ជាអ្នកបួសមួយអង្គនឹងគេដែរក្នុងព្រះពុទ្ធសាសនា ។

តំណែង ដែលមន្ត្រីសង្ឃអង្គខ្លះបានទទួល គឺមិនស៊ីគ្នានឹងចំណេះដឹងដែលលោកមានទេ **ឧទាហរណ៍:** អង្គខ្លះ

គ្មានចំណេះអីសោះ តែមានតំណែងយ៉ាងធំ ហើយអង្គខ្លះទៀតរៀនបានយ៉ាងខ្ពស់ តែបែរជាគ្មានតំណែងអីសោះក្នុងសង្គម ដូច្នេះ ខ្ញុំអាចសន្និដ្ឋានបានថា មានមន្ត្រីសង្ឃមួយចំនួនបានបម្រើសាសនា និងសង្គមជាតិល្អសមរម្យហើយ តែមន្ត្រីសង្ឃមួយចំនួនទៀត ព្រោះហេតុតែខ្វះចំណេះដឹងបានជាអសកម្មក្នុងការបម្រើជាតិ សាសនា ។

**សំណូមពរ:** សូមថ្នាក់ដឹកនាំពុទ្ធសាសនា មេត្តាពិនិត្យទៅលើកម្រិតវប្បធម៌ សមត្ថភាពជាមុនសិន មុននឹងផ្តល់តំណែងឋានៈបុណ្យសក្តិ បើពុំដូច្នោះទេសង្គមសាសនានៅកម្ពុជានឹងមានភាពអសកម្ម ព្រមទាំងមានអធិករណ៍កើតឡើងជាបន្តបន្ទាប់មិនចេះចប់មិនចេះហើយ ដូចមានករណីកើតឡើងថ្មីៗ **នៅវត្តឈ្នះមានជ័យ ឃុំឈ្នះមានជ័យ ស្រុកព្រះនេត្រព្រះ ខេត្តបន្ទាមានជ័យ** កាលពីថ្ងៃទី ០២ កក្កដា ឆ្នាំ២០១៨ មានលោកមួយអង្គនាម **ខាត់ សុទី** បានយកខ្សែភ្លើងចក់ និងយកទឹកក្តៅស្រោចទៅលើខ្លួនកុមារ **តន រតនា** ជាកូនសេក្ខដែលមានអាយុទើបតែ ៩ ឆ្នាំប៉ុណ្ណោះ។




រឿងនេះ វាជាករណីថ្មីឃោរឃៅព្រៃផ្សៃ ដែលកើតមានចំពោះអ្នកបួស ដែលច្បាប់សាសនា ច្បាប់រដ្ឋ សង្គមស៊ីវិល និងយើងទាំងអស់គ្នាគិតថាមិនគួរ សូម្បីតែរូបខ្ញុំផ្ទាល់ក៏គិតថាមិនគួរដែរ ហើយអាណិតកុមាររូបនេះស្ទើរស្រក់ទឹកភ្នែក ។ តែអ្វីដែលខ្ញុំភ្ញាក់ផ្អើលនុ៎ះ គឺឃើញទូរទស្សន៍ វិទ្យុ កាសែតបានផ្សព្វផ្សាយយ៉ាងពេញទំហឹង គួរឲ្យកោតសរសើរដែលធ្វើឲ្យកុមារជាជនរងគ្រោះមានយុត្តិធម៌ និងមានជំនួយដល់កុមារនេះផងដែរ ហើយចំណែកលោកដែលធ្វើ

អំពើអាក្រក់ ត្រូវបានថ្នាក់ដឹកនាំសង្ឃផ្សឹក ខណៈដែលទោសក្នុងព្រះពុទ្ធសាសនាមិនមានទម្ងន់ដល់សោះ ហើយបន្ទាប់ពីមក ត្រូវបានសមត្ថកិច្ចចាប់បញ្ជូនខ្លួនទៅកាន់ពន្ធនាគារ។ បន្ថែមពីលើនេះទៀត ទោសរបស់លោកធ្វើឲ្យកេរ្តិ៍ឈ្មោះ អសោចិ៍ហោះប៉ើងចេញយ៉ាងទាន់ហន់ ពីមាត់មហាជនដូចព្យុះសង្ឃរា ហើយមិនត្រឹមតែខ្ទាតខ្ទាយចេញប៉ះតែខ្លួនលោកមួយអង្គប៉ុណ្ណោះទេ ថែមទាំងរាលដាលប្រឡាក់ព្រះសង្ឃដែលប្រព្រឹត្តល្អៗ ក្នុងប្លុកព្រះពុទ្ធសាសនាថែមទៀត ជាពិសេសខ្ទាតចំមុខបណ្ដាមន្ត្រីឡើងស្លឹកមុខពេញប្រទេស ។ ខ្ញុំសូមឆ្លៀតក្នុង ឱកាសនេះជំរុញដល់ថ្នាក់ដឹកនាំជាតិ សាសនា ជួយពង្រឹង និងពង្រីកចំណេះដឹងដល់អ្នកបួស និងប្រជាពលរដ្ឋ ជាពិសេសសូមបង្កើតសាលារៀនផ្ដល់ប្រាក់ខែគ្រូឲ្យបានសមរម្យ និងរកយុត្តិធម៌ដល់ជនរងគ្រោះដទៃៗទៀតដូចរូបកុមារនេះផង៕

(សរសេរចម្ងដោយសាមណេរ **សុវណ្ណាប្បញ្ញោ ស្វាត់ សុជើត**)

អត្ថបទសម្រង់និងរៀបរៀងអធិប្បាយដោយ

ព្រះមហាធម្មាលង្ការោ **ចាន់ សុជន**

ប្រធានកម្មវិធីធាធីសំឡេងព្រះធម៌

**វត្តប្រាសាទស្រះកណ្តាល( ខ្ជាស់ )**

ចានពិនិត្យ

និងឯកភាព

*ធ្វើនៅវត្តប្រាសាទស្រះកណ្តាល(ខ្ជាស់)*

*ថ្ងៃ១៥កើត ខែអាសាឍ ព.ស.២៥៥៨*

*ត្រូវនឹងថ្ងៃសុក្រ ទី១១ ខែកក្កដា ឆ្នាំ២០១៤*